ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ៤២៣៧ ធទឧ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតលេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់

## ប្រធានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៧ ស្តីពី ការបង្កើតគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់
- បានឃើញសេចក្តីសម្រេចលេខ ១៦១ សសរ.ធទឧ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០៦ ស្តីពី ការបង្កើតលេខាធិការដ្ឋាន នៃគណៈកម្មការគ្រប់គ្រងធនធានខ្សាច់
- បានឃើញការចាំបាច់របស់គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់

## ស ម្រេ ច

**ប្រការ ១ :**

ត្រូវបានបង្កើតលេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ រួមមានសមាសភាព ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម ម៉ុន ម៉ារ៉ាន | អគ្គនាយកកិច្ចការបច្ចេកទេសក្រសួងធនធានទឹក និងឧតុនិយម | ប្រធាន |
| ២- | ឯកឧត្តម ស៊ិន នុឌ្ឍី | អគ្គាធិការក្រសួងធនធានទឹក និងឧតុនិយម | អនុប្រធាន |
| ៣- | លោក ចាន់ យុត្តា | នាយកខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី | សមាជិកអចិន្ត្រៃយ៍ |
| ៤- | ឯកឧត្តម ហ៊ី ឆាទី | អគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ | សមាជិក |
| ៥- | លោក ឡុង នុដ | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៦- | លោក ម៉ៅ ហាក់ | ប្រធាននាយកដ្ឋានជលសាស្ត្រនិងការងារទន្លេ ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |

៧- លោក **យស មុនីរ៉ាត់** ប្រធាននាយកដ្ឋានធនធានរ៉ែ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

៨- លោកស្រី **ជូ សុខដានី** ប្រធាននាយកដ្ឋានអង្កេតពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៃក្រសួងបរិស្ថាន សមាជិក

៩- លោក **មុយ មុនិន្ទ** អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងធនធានទឹក និងឧតុនិយម សមាជិក

១០- លោក **ជា សុខនី** នាយខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី សមាជិក

១១- លោក **សុខ សំអុន** មន្ត្រីនាយកដ្ឋានរៀបចំដែនដី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

**ប្រការ ២ :**

លេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ មានភារកិច្ចដូចតទៅ :

- ជាសេនាធិការឱ្យគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់
- ទទួលរៀបចំផែនការការងារ និងកិច្ចប្រជុំរបស់គណៈកម្មាធិការ
- សម្របសម្រួល និងទំនាក់ទំនងជាមួយបណ្តាក្រសួង ស្ថាប័ន ដែលជាសមាជិករបស់ គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់
- បំពេញការងារផ្សេងៗទៀត តាមការណែនាំរបស់គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់

**ប្រការ ៣ :**

លេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ និងឯកឧត្តម អស់លោក លោកស្រី ដែលមានឈ្មោះចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី 27 ខែ 06 ឆ្នាំ ២០០៧

ប្រធាន

**លឹម គានហោ**

**ចំលងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី ✓
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងពាណិជ្ជកម្ម
- ទីចាត់ការគយ និងរដ្ឋាករ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សាលាខេត្ត......................

"ដើម្បីជូនជ្រាប"

- ដូចក្នុងប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ